## “អ.វ.ត.ក នៅលើផ្លូវខ្វែង: ធ្វើឱ្យការចូលរួមរបស់ជនរងគ្រោះមានអត្ថន័យ នៅមុនពេលបើកសវនាការសំណុំរឿង០០២”

## ឯកសារគោលរបស់អង្គការសង្គមស៊ីវិល

*ភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០*

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបំបែកនូវឯកត្តកម្មថ្មីមួយ នៅពេលដែលអង្គជំនុំជម្រះនេះ បានតាក់តែងវិធានផ្ទៃក្នុងរបស់ខ្លួននៅឆ្នាំ ២០០៧ ដែលអនុញ្ញាតឱ្យមានការចូលរួមរបស់ជនរងគ្រោះ។ អង្គជំនុំជម្រះអាចជួបនឹងភាពប្រថុយប្រថានរយៈពេលបីឆ្នាំក្រោយមកទៀត ដែលអាចនាំឱ្យអន្តរាយដល់អ្វីដែលជាចំណុចសំខាន់ដែលបានសន្យា ប្រសិនបើខ្លួនមិនបង្ហាញនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំ និងចាត់វិធានការឱ្យបានហ្មត់ចត់ ដើម្បីទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនានា ព្រមទាំងស្វែងរកនូវមធ្យោបាយសំខាន់ៗ ដែលអាចគេចូលរួមនៅដំណើរការនីតិវិធីរបស់សាលាក្តីនេះប្រកបដោយអត្ថន័យទេនោះ។

អ.វ.ត.ក បានបង្ហាញនូវចំណុចជោគជ័យដ៏សំខាន់មួយនៅក្រោយពេលខ្លួនបានបើកសវនាការកាត់សេចក្តី និងបានចេញសាលក្រមសំណុំរឿង ០០១ ប្រឆាំងនឹងលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ វា គឺជាភាពជោគជ័យលើកដំបូង ដែលប្រជាជនកម្ពុជាជាច្រើនមើលឃើញដោយសារតាមដានតាមរយៈប្រព័ន្ធព័ត៌មានផ្សេងៗ។ ប៉ុន្តែទន្ទឹមនឹងនេះ ទិដ្ឋភាពខ្លះៗ នៃសាលក្រមដែលបានចេញដោយអង្គជំនុំជម្រះសាលាដំបូងនេះ ក៏បានធ្វើឱ្យមានការខកចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើន នៃ របបខ្មែរក្រហម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មានជនរងគ្រោះជាច្រើនបានបង្ហាញនូវកំហឹងក្រេវក្រោធ និងភាពមិនសប្បាយចិត្ត នៅប៉ុន្មានថ្ងៃក្រោយពីសាលក្រម ឌុច ត្រូវបានប្រកាស។ ប្រតិកម្មទាំងនេះកាន់តែបង្ហាញនូវសេចក្តីត្រូវការឱ្យមានយុទ្ធសាស្ត្រផ្សព្វផ្សាយរបស់តុលាការដែលមានលក្ខណៈសកម្មជាងមុន ដើម្បីជួយត្រៀមបំរុងនូវដំណើរការចូលរួមរបស់ជនរងគ្រោះឱ្យបានកាន់តែល្អប្រសើរថែមទៀត ជាពិសេស នៅពេលសវនាការជំនុំជម្រះក្តីនៅពេលខាងមុខទៀតនេះ ព្រមទាំង ដើម្បីជួយពន្យល់ដល់ជនរងគ្រោះទាំងនោះឱ្យយល់ដឹងកាន់តែច្បាស់លាស់ថែមទៀតអំពីដំណើរការនីតិវិធីរបស់សាលាក្តីនេះ ផងដែរ។ ជាងនេះទៅទៀត តុលាការបានខិតខំធ្វើការថ្លឹងថ្លែងរវាង ភាពមានកិរិតនៃ យន្តការដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងការជួយគាំទ្រជនរងគ្រោះជាទូទៅតាមរយៈការផ្តល់នូវអាណត្តិដ៏រឹងមាំទៅឱ្យអង្គភាពគាំពារជនរងគ្រោះ ដើម្បីអនុវត្តនូវវិធានការនានាដែលមិនមានលក្ខណៈផ្លូវច្បាប់។ ប៉ុន្តែ រហូតមកដល់ពេលបច្ចុប្បន្ននេះ គេនៅមិនទាន់ឃើញមានភាពរីកចំរើនជឿនលឿន នៃ ការប្តេជ្ញាចិត្តនេះនៅឡើយទេ។

ជាមួយនឹងការមកដល់ នៃកិច្ចប្រជុំពេញអង្គរបស់ចៅក្រម នៃ អ.វ.ត.ក នៅសប្តាហ៍នេះ តំណាងអង្គការសង្គមស៊ីវិលដែលរួមមាន គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) សម្ព័ន្ធសិទ្ធិមនុស្សអន្តរជាតិ (FIDH) និង គំរោងយុត្តិធម៌នៅកម្ពុជា (CJI) សូមអំពាវនាវដល់តុលាការមេត្តារៀនសូត្រអំពីមេរៀន ដែលបានកើតនាពេលកន្លងមក ដើម្បីបំពេញភាពខ្វះចន្លោះនៅក្នុងប្រព័ន្ធបច្ចុប្បន្ន និង ដើម្បីត្រៀមរៀបចំការចូលរួមរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីប្រកបដោយអត្ថន័យសំរាប់សវនាការកាត់សេចក្តីសំណុំរឿង០០២ ដែលជាសំណុំរឿងដ៏សំខាន់បំផុត។ ជាពិសេស យើងសូមស្នើឱ្យមានការកែលំអនូវបញ្ហាសំខាន់ៗចំនួនបី គឺ: ការងារផ្សព្វផ្សាយ, សំណង និង ជំនួយប្រកបដោយប្រសិទ្ធិភាពតាមរយៈអង្គភាពគាំពារជនរងគ្រោះ។

**ទី១- ធ្វើឱ្យប្រសើរ និងពង្រីកការងារផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងៗទៀត**

នៅក្នុងសាលក្រមជាលើកដំបូងរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងមិនបានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ២៤នាក់ នៅក្នុងចំណោម៩០នាក់ដែលបានដាក់ពាក្យបណ្តឹង ដែលសេចក្តីសំរេចចេញចេញតំណាលគ្នានឹងការប្រកាសសាលក្រម តែម្តងបន្ទាប់ពីអ្នកដាក់ពាក្យប្តឹងផ្សេងទៀតដែលត្រូវបានបដិសេធ បានចូលរួមនៅក្នុងដំណើរការនីតិវិធីអស់ជាងពីរឆ្នាំកន្លងមក ហើយនោះ។ សាលក្រមនេះបានផ្តល់នូវគោលការណ៍ក្នុងការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីដ៏ជាក់លាក់មួយ ហើយ ដែលខ្លឹមសារលំអិតរបស់វាមិនដែលត្រូវបានផ្សព្វផ្សាយឱ្យបានច្បាស់លាស់ទៅដល់អ្នកដាក់ពាក្យសុំទាំងនោះឡើយ ចាប់តាំងពីពេលមុនមក។ រឿងដូចគ្នានេះក៏មានដដែល នៅពេលសហចៅក្រមស៊ើបអង្កេតបានចេញផ្សាយនូវសេចក្តីសំរេចនាពេលថ្មីៗនេះ ទាក់ទិននឹងការទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២។ យើងយល់ថា ការកំណត់បែបនេះជារឿងសមរម្យ ប្រសិនបើលក្ខណៈវិនិច្ឆ័យនានាក្នុងការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបញ្ជាក់តាំងពីដំបូង ហើយត្រូវបានពន្យល់ផ្សព្វផ្សាយទៅដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានសក្តានុពល បានច្បាស់លាស់នោះ។ ប៉ុន្តែ ផ្ទុយទៅវិញ តុលាការមិនបានចេញគោលការណ៍ណែនាំច្បាស់លាស់តាំងពីពេលចាប់ផ្តើមដំណើរការ ដើម្បីឱ្យអ្នកដាក់ពាក្យបណ្តឹងអាចយល់ដឹងច្បាស់លាស់អំពីមូលដ្ឋាន និងភាពមានកិរិតនៃការចូលរួមរបស់ខ្លួនក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ឡើយ។

ដូចនេះមានតែការផ្សព្វផ្សាយដែលមានលក្ខណៈសកម្មជាងមុនទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីទេ ទើបអាចជួយកែសំរួលនូវទំនាក់ទំនងដែលមិនត្រឹមត្រូវនាពេលកន្លងមកបាន ព្រមទាំងអាចឱ្យយើងគ្រប់គ្រងនូវក្តីរំពឹងទុកនានារបស់អ្នកដែលចូលរួមនៅក្នុងដំណើរការបានល្អប្រសើរជាងមុន ក៏ដូចជា ទទួលស្គាល់នូវភាពរងគ្រោះរបស់គេបានត្រឹមត្រូវផងដែរ។ ជាជំហានដំបូងនៅពេលនេះ យើងសូមផ្តល់យោបល់ទៅកាន់តុលាការឱ្យអញ្ជើញអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ដែលត្រូវបានបដិសេធ គឺអ្នកមកពីទីណាតាមដែលអាចធ្វើបាន មកកាន់ទីតាំងតុលាការ។ យើងជឿជាក់ថា វិធីដែលសមរម្យ និងដ៏គួរឱ្យគោរពចំពោះអ្នកដាក់ពាក្យបណ្តឹង គឺការទទួលបាននូវការពន្យល់ឱ្យបានត្រឹមត្រូវអំពីឋានៈរបស់គេពីសហចៅក្រមស៊ើបអង្កេត។ យុទ្ធសាស្ត្របែបនេះនឹងអាចឱ្យជនរងគ្រោះមានការយល់ដឹងច្បាស់លាស់អំពីភាពមានកិរិតនៃដំណើរការនីតិវិធីផ្លូវច្បាប់របស់តុលាការ ហើយសំខាន់ជាងនេះទៀត វាក៏បង្ហាញនូវសញ្ញាណរឹងមាំចំពោះការទទួលស្គាល់នូវការចូលរួមវិភាគទានរបស់គេនៅក្នុងនីតិវិធីតុលាការនេះ។ លើសពីនេះទៀត ការធ្វើបែបនេះ ក៏យ៉ាងហោចណាស់ផ្តល់ឱកាសឱ្យជនរងគ្រោះទាំងនេះបានមកឃើញទីតាំងសាលាក្តីដោយផ្ទាល់ម្តង ផងដែរ។

**ទី២- ធ្វើឱ្យសំណងផ្លូវចិត្ត និងសមូហភាពលេចចេញរូបរាងជាក់ស្តែង**

ការប្រកាសផ្តល់សំណងរដ្ឋប្បវេណីដោយអង្គជំនុំជម្រះសាលាដំបូង បានគ្រាន់តែបន្ថែមទៅនឹងការខកចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលបានចូលរួមនៅក្នុងសំណុំរឿង០០១។ អង្គជំនុំជម្រះសាលាដំបូងបានគ្រាន់តែសន្យាបង្គាប់ឱ្យមានការបោះផ្សាយនូវឈ្មោះរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី និងចងក្រងនូវពាក្យសំដីសុំអភ័យទោស និងការសំដែងវិប្បដិសារីរបស់ពិរុទ្ធជន ឌុច ដែលជាការជួសជុលមួយមិនអាចឆ្លើយតបទាល់តែសោះទៅនឹងសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ សេចក្តីសំរេចភាគច្រើនរបស់ចៅក្រមនៅក្នុងសាលក្រមនេះ គឺដោយសារតែភាពមានកិរិតរបស់វិធានផ្ទៃក្នុងបច្ចុប្បន្ន។ ដូចនេះ ប្រតិកម្មនានារបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលកំពុងតែមាននាពេលនេះ បាននិងកំពុងដាក់សម្ពាធទៅលើ

តុលាការនេះឱ្យធ្វើវិសោធនកម្មទៅលើវិធានផ្ទៃក្នុងរបស់ខ្លួន និងផ្តល់នូវភាពបត់បែនជាងមុន ដើម្បីធ្វើឱ្យសំណងលេចចេញរូបរាងជាក់ស្តែង យ៉ាងហោចណាស់ក៏សំរាប់ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០២ដែរ។

តាមរយៈកិច្ចប្រជុំពេញអង្គចៅក្រមចំនួនពីរលើកមកហើយ ដែលសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ដើម្បីពង្រួញការចូលរួមរបស់ជនរងគ្រោះកុំឱ្យមានច្រើនពេកសំរាប់សំណុំរឿង០០២ នាពេលខាងមុខ។ ទោះបីការកែសំរួលកាលពីលើកមុនមួយចំនួនចាំបាច់ ប៉ុន្តែឥឡូវនេះ យើងមើលឃើញនូវការទទួលខុសត្រូវរបស់ចៅក្រម នៃ អ.វ.ត.ក ដែលត្រូវខិតខំប្រឹងប្រែងដូចគ្នា ដើម្បីធ្វើយ៉ាងណាឱ្យការចូលរួមរបស់ជនរងគ្រោះមានអត្ថន័យក្នុងការទាមទារនូវសំណងផ្លូវចិត្ត និងសមូហភាព ដែលយោងតាមគោលការណ៍ជាមូលដ្ឋានស្តីពី សិទ្ធិទទួលបានការជួសជុលសំណងសំរាប់ជនរងគ្រោះដោយអំពើរំលោភធ្ងន់ធ្ងរនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ។ បញ្ហាសំណងដដែលនេះ នឹងជាប្រធានរឿងដ៏សំខាន់សំរាប់របៀបប្រជុំរបស់កិច្ចប្រជុំពេញអង្គចៅក្រមនៅសប្តាហ៍នេះ ហើយវាក៏ជាប្រធានបទមួយដែលទើបតែត្រូវបានរៀបចំកិច្ចពិគ្រោះពិភាក្សាផងដែរ នៅក្នុងចំណោមអ្នកតំណាងមួយចំនួនជាអាទិ៍៖ ដើមបណ្តឹងរដ្ឋប្បវេណី, មេធាវីដើមបណ្តឹង និងអង្គការសង្គមស៊ីវិល កាលពីសប្តាហ៍កន្លងទៅនេះ។

យើងទទួលស្គាល់ថា វាពិតជាមានបញ្ហាប្រឈមជាច្រើនសំរាប់ឱ្យ អ.វ.ត.ក បង្កើតឱ្យបាននូវដំណើរការនីតិវិធីសំរាប់សំណងដែលមានលក្ខណៈសមស្របទៅនឹងអាណត្តិរបស់ខ្លួន និងគោរពសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដ៏ឃោរឃៅ ក្នុងការទទួលបាននូវសំណងជួសជុលឱ្យបានសមរម្យ ហើយនៅស្របពេលគ្នានេះសំណងបែបនេះ ក៏ត្រូវតែស្របទៅនឹងការពិតជាក់ស្តែងផងដែរ។ ដូចនេះ យើងសូមជំរុញដល់ចៅក្រម នៃ កិច្ចប្រជុំពេញដាក់បញ្ចូលនូវអាណត្តិ ដែលមានលក្ខណៈទន់ភ្លន់បត់បែនជាងនេះសំរាប់បង្គាប់សំណងដោយតុលាការ ជាពិសេស គឺពិនិត្យមើលលើសពីអ្វី ដែលគ្រាន់តែបន្ទុកនៃការទទួលខុសត្រូវរបស់ជនជាប់ចោទម្នាក់ៗ ហើយដាក់បញ្ចូលបន្ថែមនូវមធ្យោបាយពីរទៀតសំរាប់ឱ្យមានយន្តការអនុវត្តសំណងផងដែរ។ តាមទស្សនៈរបស់យើង វិសោធនកម្មទៅលើចំណុចសំខាន់ៗទាំងនេះ នឹងអនុញ្ញាតឱ្យអង្គជំនុំជម្រះធ្វើការពិចារណាទៅលើក្របខណ្ឌដែលបានឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តយ៉ាងជាក់ច្បាស់របស់តុលាការក្នុងការធានាឱ្យមានសំណងផ្លូវចិត្ត និងសមូហភាពផ្តល់ជូនដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ជាក់ស្តែង តុលាការអាចចេញអនុសាសន៍ជូនដល់រដ្ឋ និងអនុម័តយល់ព្រមទៅលើទំរង់នៃសំណងសមូហភាពដែលអាចបត់បែនបានមួយចំនួន ក៏អាចជាការទទួលស្គាល់ជនរងគ្រោះ នៃរបបខ្មែរក្រហម ផងដែរ។ ប្រសិនបើមិនដូច្នោះទេ អ.វ.ត.ក នឹងជួបនូវភាពប្រថុយប្រថានក្នុងការសំរេចឱ្យបាននូវកេរ្តិ៍ដំណែលវិជ្ជមានសំរាប់ជនរងគ្រោះជាអ្នករស់រានមានជីវិត ជាមិនខាន។

### ទី៣- ផ្តល់អំណាចដល់អង្គភាពគាំពារជនរងគ្រោះដើម្បីអនុវត្តនូវអាណត្តិរបស់ខ្លួនឱ្យបានពេញលេញ

ការស្នើសុំរបស់យើងភាគច្រើន ក៏ពឹងផ្អែកទៅលើការបំពេញមុខងារដ៏មានប្រសិទ្ធិភាពនៃអង្គភាពគាំពារជនរងគ្រោះដែលអង្គភាពនេះ ចាំបាច់ត្រូវតែដើរតួនាទីដឹកនាំដំណើរការនៃចូលរួមរបស់ជនរងគ្រោះនៅអ.វ.ត.ក។ ទោះបីជានៅប៉ុន្មានខែកន្លងមកនេះ អង្គភាពនេះសំរេចបាននូវការងារដ៏ចំបងៗ ដូចជា ការរៀបចំបំពេញបែបបទពាក្យបណ្តឹង និងរៀបចំឱ្យមានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីរួចហើយក៏ដោយ ក៏យើងជឿជាក់ថា អង្គភាពនេះ ត្រូវតែទទួលបាននូវការផ្តល់នូវអំណាចថែមទៀត ដើម្បីឱ្យបំពេញអាណត្តិមុខងារទាំងអស់របស់ខ្លួនដូចដែលបានចែងនៅក្នុងវិធានផ្ទៃក្នុង។ ពេលវេលាអស្ថេរភាពដែលបង្កឡើងដោយការផ្លាស់ប្តូរថ្នាក់ដឹកនាំ គួរតែត្រូវបញ្ឈប់ ហើយយើងក៏សូមអំពាវនាវដល់ការិយាល័យរដ្ឋបាលធានាថា អង្គភាពគាំពារជនរងគ្រោះទទួលបាននូវការគាំទ្រ និងមធ្យោបាយសំរាប់ជួយដល់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះដទៃ។

ដូចនេះ នៅមុនពេលដំណើរការកាត់សេចក្ដីសំណុំរឿង ០០២ ដែលរំពឹងថានឹងអាចមាននៅដើមឆ្នាំក្រោយ អង្គភាពគាំពារជនរងគ្រោះចាំបាច់ត្រូវរៀបចំបង្កើតឱ្យមានផែនការយុទ្ធសាស្ត្រលំអិតមួយ ដើម្បីអនុវត្តនូវអាណត្តិមុខងាររបស់ខ្លួនដែលទើបតែពង្រីក រួមបញ្ចូលទាំង បទបញ្ញត្តិជុំវិញវិធានការនានាដែលមិនមែនតាមផ្លូវតុលាការ។ ផែនការដែលត្រូវធ្វើនោះ គួរតែធ្វើឡើងដោយមានកិច្ចពិគ្រោះពិភាក្សាជាមួយនឹងជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីរបស់គេ ព្រមទាំង អង្គការសង្គមស៊ីវិល ផងដែរ។ ចុងក្រោយ យើងក៏សូមអំពាវនាវដល់រដ្ឋាភិបាលអាឡឺម៉ង់បន្តផ្ដល់ជំនួយដល់អង្គភាពនេះជាបន្ត ទៀត។ ការបន្តជួយគាំទ្រផ្នែកថវិកាសំរាប់អង្គភាពដំណើរការ គឺជារឿងចាំបាច់ ដើម្បីធានាឱ្យមាននូវកេរ្តិ៍ដំណែលវិជ្ជមានមួយរបស់តុលាការឆ្លើយតបទៅនឹងជនគោលដៅចំបងនៃដំណើរការកាត់សេចក្ដីនេះ គឺជនរងគ្រោះនៃរបបខ្មែរក្រហមទាំងអស់។

***ខាងក្រោមនេះ គឺជាអនុសាសន៍សង្ខេបរបស់យើង:***

**ចំពោះចៅក្រមទាំងអស់របស់អង្គជំនុំជម្រះវិសាមញ្ញនៅកិច្ចប្រជុំពេញអង្គ:**

- សូមធ្វើវិសោធនកម្មវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះមានភាពទន់ភ្លន់ទូលំទូលាយ និង មានមធ្យោបាយបន្ថែមពីរទៀត ដើម្បីអនុវត្តសំណងផ្លូវចិត្ត និងសមូហភាពសំរាប់ដើមបណ្ដឹងរដ្ឋប្បវេណី។
- *ចំពោះសហចៅក្រមស៊ើបអង្កេត:* សូមផ្ដល់ព័ត៌មានដល់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នូវឋានៈរបស់គេ អញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីសំណុំរឿង ០០២ ដែលត្រូវបដិសេធ នៅទីណាដែលអាចមកបាន ឱ្យមកកាន់តុលាការ ដើម្បីពន្យល់គេដោយផ្ទាល់នូវដីកាសំរេចរបស់ខ្លួន ព្រមទាំងទទួលស្គាល់ជាផ្លូវការនូវការចូលរួមវិភាគទានរបស់គេក្នុងដំណើរការនេះ។

**ចំពោះការិយាល័យរដ្ឋបាលរបស់តុលាការ និងអង្គភាពគាំពារជនរងគ្រោះ**

- សូមធានាថា អង្គភាពគាំពារជនរងគ្រោះមានការគាំទ្រពេញលេញ មានថ្នាក់ដឹកនាំដែលស្ថិតស្ថេរ មានធនធានសំរាប់ដំណើរការគ្រប់គ្រាន់ និង មានផែនការយុទ្ធសាស្ត្រមួយ សំរាប់អនុវត្តអាណត្តិរបស់ខ្លួន ដើម្បីជួយគាំទ្រដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងៗទៀត។
- សូមជំរុញការងារផ្សព្វផ្សាយឱ្យបានល្អប្រសើរឡើងថែមទៀតទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី និង ជនរងគ្រោះដទៃទៀត តាមរយៈការអនុវត្តនូវយុទ្ធសាស្ត្រដែលមានលក្ខណៈសកម្មជាងមុន ដែលអាចផ្ដល់ព័ត៌មានពួកគេគ្រប់គ្រាន់, គ្រប់គ្រងនូវការរំពឹងទុករបស់គេ ក៏ដូចជាផ្ដល់នូវការទទួលស្គាល់ចំពោះការចូលរួមរបស់គេ។
- សូមផ្ដល់នូវការគាំទ្រឱ្យបានគ្រប់គ្រាន់ដល់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី និង អនាគតសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីតំណាងកូនក្ដីរបស់គេស្របទៅតាមអាណត្តិរបស់គេយ៉ាងត្រឹមត្រូវ។
- សូមចាប់ផ្ដើមរៀបចំ ធ្វើផែនការ និងអនុវត្តវិធានការនានាដែលមិនមែនតាមផ្លូវតុលាការសំរាប់ជាប្រយោជន៍ដល់ជនរងគ្រោះ។

**ចំពោះម្ចាស់ជំនួយនានា**

- *ចំពោះម្ចាស់ជំនួយទាំងអស់:* សូមបំពេញតាមការប្ដេជ្ញាចិត្តរបស់ខ្លួនដែលបានធ្វើឡើងនៅក្នុងពេលបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបន្តផ្ដល់ថវិកាថែមទៀតដល់សាលាក្ដីនេះ ដើម្បីឱ្យបំពេញមុខងាររបស់ខ្លួនចប់ចុងចប់ដើម រួមទាំងចំពោះជនរងគ្រោះ ផងដែរ។

- *ចំពោះម្ចាស់ជំនួយអាឡឺម៉ង់:* សូមបន្តផ្តល់ថវិកាគាំទ្រដល់អង្គភាពគាំពារជនរងគ្រោះ ហើយតាមរយៈជំនួយទ្វេភាគី GTZ ធានាថា ថវិកានេះប្រើប្រាស់ត្រឹមត្រូវបំរើផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងៗទៀត។

| | **ហត្ថលេខី** | **តួនាទី/អង្គការ-សមាគម** | **លេខទូរស័ព្ទ** |
|---|---|---|---|
| ១ | **លោក ធន សារាយ** | ប្រធានសមាគមអាដហុក (ADHOC) និងប្រធានសំរបសំរួលគណៈកម្មាធិការ ប្រព្រឹត្តិកម្ម (CHRAC)[1] | ០១៦ ៨៤០ ០៨៨ |
| ២ | **លោក ហង្ស ឆាយា** | នាយកប្រតិបត្តិវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ (KID) | ០១២ ៨៦៥ ៩១០ |
| ៣ | **លោក សុក សំអឿន** | នាយកប្រតិបត្តិអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) | ០១២ ៩០១ ១៩៩ |
| ៤ | **លោកស្រី Karine BONNEAU** | មន្ត្រី នៃ សម្ព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (FIDH) | |
| ៥ | **លោក រុន សារាយ** | នាយកប្រតិបត្តិអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) | ០១២ ៨២៣ ៧៤៥ |
| ៦ | **លោក ឡុង បញ្ញាវុឌ្ឍ** | អ្នកសំរបសំរួល គំរោងយុត្តិធម៌នៅកម្ពុជា (CJI) | ០១២ ៨៤៣ ៦៤៧ |

[1] CHRAC គឺជាសម្ព័ន្ធសមាគម-អង្គការមិនមែនរដ្ឋាភិបាលដែលមានសមាជិកចំនួន ២៣ ធ្វើការនៅក្នុងប្រទេសកម្ពុជាលើ វិស័យសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងជំនួយផ្នែកច្បាប់។